# សំឡេងកាំជ្រួចយ៉ាងខ្លាំង
## និងពណ៌ឆើតឆាយ



« *ហេតុអ្វីបានជាព្រះវរបិតាសួគ៌មិនធ្វើឲ្យសំឡេងខ្លាំងៗចេញឲ្យឆ្ងាយទៅ ? » ឆារលុត បានសួរ ។*


ហេដឌើ ស៊ូលីវ៉ាន់
( ផ្អែកទៅលើដំណើររឿងពិត )


*ដំណើររឿងនេះបានកើតឡើងនៅក្នុង ស.រ.អា. ។*

ឆារលុត ស្អប់សំឡេងខ្លាំងៗណាស់ ! នាងមិនចូលចិត្តសំឡេងដែលខ្ទរនៅក្នុងត្រចៀករបស់នាង ឬបន្លឺនៅក្នុងក្បាលរបស់នាងទេ ។ ទោះបីជានាងដឹងថានាងមានសុវត្ថិភាពក៏ដោយ ក៏នាងនៅតែមានអារម្មណ៍តានតឹងនៅពេលមានសំឡេងរថយន្តរអិល ហ្វូងមនុស្សអេបអរ ឬគោះស្គរ ។

ហើយ ឆារលុត *ពិតជា* មិនចូលចិត្តកាំជ្រួចទេ !

គ្រួសាររបស់នាងបានព្យាយាមធ្វើរឿងជាច្រើនដើម្បីលួងលោមនាង ពេលមានសំឡេងខ្លាំងៗ ។ ប៉ាបានទិញកាសត្រចៀកពិសេសឲ្យនាង ដើម្បីជួយរាំងសំឡេងរំខាន ។ ពេលមានផ្គរលាន់ ម៉ាក់បានគ្រលំភួយជាមួយនាង ។ ឆារលុត ក៏បានអធិស្ឋានទូលសុំជំនួយមិនឲ្យភ័យខ្លាចផងដែរ ។

ការណ៍ទាំងអស់នេះបានជួយ ។ ប៉ុន្តែសំឡេងខ្លាំងនៅតែធ្វើឲ្យនាងភ័យខ្លាច ។

ម៉ាក់បានប្រាប់ឆារលុតថា « យើងនឹងទៅមើលកម្មវិធីជុតកាំជ្រួចពិសេសមួយនៅសួនច្បារយប់នេះ » ។ « តើកូនចង់ទៅទេ ? »

ឆារលុត ជ្រួញចញ្ចើម « តែកាំជ្រួចឮខ្លាំងណាស់ » ។

ម៉ាក់បាននិយាយថា « ឥឡូវនេះកូនធំហើយ ដូច្នេះវាកាន់តែសប្បាយពេលកូនមើល » ។ « មិត្តរបស់កូនទាំងអស់នឹងនៅទីនោះ យើងថែមទាំងអាចយកកាសត្រចៀកពិសេសរបស់កូនទៅផងដែរ ។ តើកូនគិតថាកូនអាចសាកល្បងសិនបានទេ ? »

ឆារលុត ដកដង្ហើមធំ « យល់ព្រម ខ្ញុំនឹងសាកល្បងមើល » ។

កម្មវិធីកាំជ្រួចនៅសួនច្បារបានចាប់ផ្ដើមយ៉ាងល្អឥតខ្ចោះ ។ ឆារលុត និងមិត្តភក្តិរបស់នាងបានរត់ជុំវិញស្មៅចែករំលែកអាហារ និងលេងល្បែងកម្សាន្តជាមួយគ្នា ។ មិនយូរប៉ុន្មានមេឃកាន់តែងងឹត ។ ឆារលុត បានអង្គុយទាញកាសត្រចៀករបស់នាង នៅពេលនាងមើលទៅកាំជ្រួចនៅលើមេឃទាំងភ័យខ្លាច ។

*ក្ដាំង ! ក្ដាំង ! បែក !*

បេះដូងឆារលុតលោតញាប់ ហើយនាងតឹងណែនទ្រូង ។ នាងបានលោតឡើង ហើយព្យាយាមរត់ចេញពីសំឡេងផ្ទុះនៅជុំវិញនាង ។

ម៉ាក់បានរត់តាម ឆារលុត ហើយបីនាងឡើង ។ ពួកគេអង្គុយចុះ ហើយម៉ាក់បានឱបនាងយ៉ាងណែន ។ ឆារលុតហូរទឹកភ្នែក ។

ម៉ាក់បាននិយាយថា « ម៉ាក់សោកស្ដាយណាស់ដែលកូនភ័យខ្លាច » ។ « ម៉ាក់ នៅទីនេះ ចូរយើងផ្ដោតទៅលើពណ៌វិញ ដូច្នេះកូនមិនបាច់ផ្ដោតលើសំឡេងច្រើននោះទេ ។ តើភ្នែកកូនមើលឃើញអ្វីខ្លះ ? »

ឆារលុត បានដកដង្ហើមធំ « ខ្ញុំឃើញពណ៌មាស ក្រហម និងពណ៌បៃតង » ។

ម៉ាក់និយាយថា « ឥឡូវប្រើច្រមុះរបស់កូន » ។ « តើកូនធុំក្លិនអ្វី ? »

ឆារលុតបាននិយាយថា « កូនធុំក្លិនផ្សែង និងស្មៅ » « និង ពោតលីង ! » ។

« តើកូនអាចប្រើញ្ញាណអ្វីខ្លះទៀតឥឡូវនេះ ? »

ឆារលុត បានបិទភ្នែករបស់នាង ។ « កូនមានអារម្មណ៍ដឹងពីវត្តមានកាំជ្រួចទាំងនោះ ពេលកាំជ្រួចផ្ទុះ កូនអាចមានអារម្មណ៍ញាប់ញ័រនៅក្នុងទ្រូងកូន » ។

« តើកូនអាចភ្លក់វាបានទេ ? » ម៉ាក់បានសួរ ។

ឆារលុតបានលៀនអណ្ដាតរបស់នាង « កូនមិនអាចភ្លក់កាំជ្រួចបានទេ » ។ នាងសើច ។

ការណ៍ទាំងអស់នេះបានធ្វើឲ្យឆារលុត ចង់ដឹងចង់ឮ ។ *តើមនុស្សអាចបង្កើតពណ៌ផ្សេងៗគ្នាយ៉ាងដូចម្ដេច ?* នាងងឿងឆ្ងល់ ។ *ហេតុអ្វីបានជាកាំជ្រួចផ្ទុះ ? តើពួកគេបង្កើតរូបរាងខុសៗគ្នាយ៉ាងដូចម្ដេច ?* ឥឡូវនេះកាំជ្រួចហាក់ដូចជាមិនគួរឲ្យខ្លាចនោះទេ ។

« ម៉ាក់ កាំជ្រួចពិតជាអស្ចារ្យណាស់ ! » ឆារលុតបាននិយាយ ។

នៅពេលម៉ាក់ស្មៀកពាក់ឲ្យ ឆាតលុត ចូលគេងនៅយប់នោះ ឆារលុតបានសួរថា « ហេតុអ្វីបានជាព្រះវរបិតាសួគ៌មិនឆ្លើយតបនឹងការអធិស្ឋានរបស់កូននៅពេលកូនសុំឲ្យទ្រង់យកសំឡេងខ្លាំងៗនោះចេញ ? »

ម៉ាក់បានគិតមួយសន្ទុះ ។ ម៉ាក់បាននិយាយថា « ព្រះវរបិតាសួគ៌មិនតែងតែយករឿងគួរឲ្យខ្លាចចេញនោះទេ » ។ « ប៉ុន្តែពេលខ្លះទ្រង់ជួយឲ្យយើងមើលឃើញរឿងផ្សេងៗ ឬផ្ដល់ឲ្យយើងនូវមនុស្សដែលជួយលួងលោមយើង » ។

ឆារលុតបាននិយាយថា « ដូចជារបៀបដែលទ្រង់បានជួយកូនយប់នេះ ! » ។

« ត្រឹមត្រូវហើយ ! » ម៉ាក់បានញញឹម ។ « កូនបានទៅកម្មវិធីជុតកាំជ្រួច ទោះបីជាកូនភ័យខ្លាចក៏ដោយ ។ បន្ទាប់មក ព្រះវរបិតាសួគ៌បានជួយកូនឲ្យមានអារម្មណ៍ស្ងប់ស្ងាត់បាត់ភ័យខ្លាច ។ ទ្រង់ក៏បានជួយកូនមើលឃើញភាពស្រស់ស្អាតនៃកាំជ្រួច ដោយប្រើញ្ញាណផ្សេងទៀតរបស់កូនផងដែរ » ។

ឆារលុតបានគិតអំពីពណ៌ឆើតឆាយនៅលើមេឃ ហើយញញឹម ។ តែនាងនៅតែមិនចូលចិត្តសំឡេងខ្លាំងៗដដែល ។ វានៅតែធ្វើឲ្យនាងភ័យខ្លាច ។ ប៉ុន្តែនាងបានដឹងថាព្រះវរបិតាសួគ៌អាចជួយនាងឲ្យមានភាពក្លាហានជានិច្ច ។●

« កុំឲ្យភ័យខ្លាចឡើយ ដ្បិតយើងនៅជាមួយនឹងឯង » ( អេសាយ ៤១:១០ ) ។